00637199

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D427/1/27

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់*
*ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧៥)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នុយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 01 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ:**
**សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង សារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ឡោ ជុនធី
គង់ ពិសី

**សហមេធាវីការពារក្តីជនជាប់ចោទ**
អាង ឧត្តម
Michael G. KARNAVAS

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ហុង គីមសួន
យ៉ុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
DELAHAIE Annie
Fabienne TRUSSES-NAPROUS
ស៊ីន សុវ៉ន
វ៉េន ពៅ
BEAUDOIN Patrick
GUIRAUD Marie
LYMA NGUYEN
ជេត វណ្ណលី
DESFORGES Laure
DURAND Isabelle
GAUTRY Francoise
MARTINEAU Christine
Pascal AUBOIN
Ferdinand DJAMMEN- Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
ពេជ អង្គ

**<u>សហចៅក្រមស៊ើបអង្កេត</u>**

យូ ប៊ុនឡេង

Siegfried BLUNK

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ [របស់សហចៅក្រមស៊ើបអង្កេត]" ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")[១] ដែលបានដាក់កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសសេចក្តីសម្រេចជាស្ថាពរលើបណ្តឹងឧទ្ធរណ៍នេះ និងបានប្រកាសឲ្យបានដឹងជាមុនថា សេចក្តីសម្រេចដែលមានសំអាងហេតុចំពោះបណ្តឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមពេលវេលាសមស្រប។

២. ជាពិសេស **អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ៖**

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីប្រាំ ទីប្រាំពីរ (មួយផ្នែក) និងទីដប់មួយ (មួយផ្នែក) អាចទទួលយកបាន។ មូលដ្ឋានដែលនៅសល់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ។

៣. មូលដ្ឋានទីមួយ ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរ ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបី ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីប្រាំ ត្រូវបានបដិសេធ។

៧. មូលដ្ឋានទីប្រាំពីរ ដូចដែលវាអាចទទួលយកបាន ត្រូវបានអនុញ្ញាតចំពោះផ្នែកខ្លះ រីឯផ្នែកផ្សេងពីនេះត្រូវបានបដិសេធ។

១. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវី

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6។ ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")។

ការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានពុំបានធ្វើការពិចារណាថា ក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឲ្យមានចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវបានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងផ្នែកទីIV(ក) ជំពូកបី នៃដីកាដំណោះស្រាយ។

២. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

៨. មូលដ្ឋានទីដប់មួយ ដូចដែលវាអាចទទួលយកបាន ត្រូវបានបដិសេធ។

៩. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១០. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឲ្យបញ្ជូនខ្លួនទៅជំនុំជម្រះ ដូចបាន ចែងនៅ ក្នុងដីកាដំណោះស្រាយ ដែលត្រូវអានព្រមគ្នាជាមួយនឹងសាលដីកានេះ។

១១. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ត្រូវបានបង្គាប់ឲ្យបន្តថិរវេលារហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុ ចំពោះសេចក្តីសន្និដ្ឋានទាំងដប់មួយ នៃសាលដីកានេះ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ដែលការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ ត្រូវបានបង្គាប់ឱ្យបន្តឃុំខ្លួន។

## ការរក្សាការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ: សំអាងហេតុ

៤. អនុលោមតាមអនុវិធាន៦៨(២) នៅពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ មិនថាលក្ខណៈនៃបណ្តឹងឧទ្ធរណ៍នោះយ៉ាងណាទេ "អានុភាពនៃដីកាឃុំខ្លួន ឬដីកាដោះលែងជន ត្រូវចោទឱ្យនៅក្រៅឃុំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តរហូតដល់មានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ"។

៥. ជាបន្ថែមទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលជាកម្មវត្ថុនៃការចេញសេចក្តីសម្រេចនេះ ជនជាប់ចោទបានដាក់បណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកមួយ ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃឃុំខ្លួនគាត់បណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃការឃុំខ្លួនគាត់បណ្តោះអាសន្ន")[២]។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃការឃុំខ្លួនគាត់បណ្តោះអាសន្ន ត្រូវបានបដិសេធចោលនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដោយហេតុនោះ អង្គបុរេជំនុំជម្រះបានប្រកាសសេចក្តីសម្រេចជាស្ថាពរលើបណ្តឹងឧទ្ធរណ៍នេះ និងបានប្រកាសឱ្យបានដឹងជាមុនថា សេចក្តីសម្រេចដែលមានសំអាងហេតុចំពោះបណ្តឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមពេលវេលាសមស្រប[៣]។ សំអាងហេតុទាំងឡាយសម្រាប់សេចក្តីសម្រេចនេះ ត្រូវបានផ្តល់រួចហើយក្នុងថ្ងៃនេះ[៤]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានពន្យល់ហេតុ ដែលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្នបានខកខានបង្ហាញថា សហចៅក្រមស៊ើបអង្កេត មានការភ័ន្តច្រឡំនៅក្នុងការចេញដីកាសម្រេចរបស់ខ្លួន ដើម្បីរក្សាជនជាប់ចោទនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។

---

[២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃឃុំខ្លួនគាត់បណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/5/1។

[៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃឃុំខ្លួនគាត់បណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/9។

[៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលា នៃឃុំខ្លួនគាត់បណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/10។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានកាលៈទេសៈពិសេសណាមួយ ចាប់តាំងពីការចេញដីកាដំណោះស្រាយដោយសហចៅក្រមស៊ើបអង្កេត ក្រៅពីការអះអាងលើការបញ្ជូនរឿងទៅជំនុំជម្រះពីអង្គបុរេជំនុំជម្រះ ដែលធ្វើឱ្យរឹងមាំពីមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយវាក៏ធ្វើឱ្យរឹងមាំផងដែរពីភាពចាំបាច់ ដើម្បីរក្សាគាត់ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្ដាប់ធ្នាប់សាធារណៈ[៥]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុដែលផ្ដល់ឱ្យដោយសហចៅក្រមស៊ើបអង្កេត ដើម្បីបង្គាប់ថា ជនជាប់ចោទរក្សាការឃុំខ្លួនបណ្ដោះអាសន្ន ដែលអង្គជំនុំជម្រះយកតាម មានយុត្តិកម្មថា អង្គជំនុំជម្រះបង្គាប់ថា ការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្នត្រូវបានបង្គាប់ឱ្យបន្តថិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**ភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១**

**អង្គបុរេជំនុំជម្រះ** ប្រធាន

**Rowan DOWNING** **ន័យ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

---

[៥] វិធានផ្ទៃក្នុង ៦៣(៣)(ខ) (១) (២) (៣)និង(៤)។